# សុន្ទរកថារបស់ **ឯកឧត្តម ម៉ាសាហ៊្វូមី គូរ៉ូគី**

ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន
២០ ធ្នូ ២០១២

- **សូមគោរព លោក ឈ ភឿន ប្រធានអង្គការជួយសេវាពេទ្យកម្ពុជា(CMSSO)**
- **សូមគោរព អស់លោក លោកស្រី!**

ជាបឋមខ្ញុំសូមសំដែងនូវមរណៈទុក្ខដ៏ក្រៀមក្រំជាមួយព្រះញាតិវង្សានុវង្ស រាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជាចំពោះការយាងចូលព្រះទីវង្គតនៃព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបិតាឯករាជ្យជាតិខ្មែរ។

ថ្ងៃនេះយើងបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយអង្គការជួយសេវាពេទ្យកម្ពុជា(CMSSO) សម្រាប់គម្រោង សាងសង់អគារមន្ទីរពេទ្យ និង បំពាក់សម្ភារៈបរិក្ខារពេទ្យក្នុងមន្ទីរពេទ្យបង្អែកស្រុកបរកែវ ខេត្តរតនគីរី។

ការកែលម្អសេវាសុខាភិបាលគឺជាកត្តាអាទិភាពចម្បងមួយក្នុងចំណោមកត្តាអាទិភាពជាគោលដៅសម្រាប់អភិវឌ្ឍប្រទេសកម្ពុជាដែលរាជរដ្ឋាភិបាលបាននិងកំពុងរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍវិស័យសុខាភិបាលនៅទូទាំងប្រទេស។ ការកែលម្អឲ្យប្រសើរឡើងនូវស្ថានភាពសុខាភិបាលនឹងរួមចំណែកដល់ការពង្រឹងសមត្ថភាពធនធានមនុស្ស និងជួយសម្រួលដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។

រដ្ឋាភិបាលជប៉ុនបានទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យសុខាភិបាល ហើយបាននិងកំពុងបន្តជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលសាធារណៈ ក៏ដូចជាការផ្តល់នូវការបណ្តុះបណ្តាលអ្នកជំនាញសុខាភិបាលជាដើម។

ជំនួយសរុបចំនួន ១០០,២៩៨ដុល្លាអាមេរិកដែលផ្តល់ជូនថ្ងៃនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់អគារមន្ទីរពេទ្យដែលមាន៦បន្ទប់សម្រាប់ផ្នែកជំងឺកុមារ ផ្នែកសម្រាកព្យាបាល ផ្នែកបន្ទប់ពិសោធន៍ និងបន្ទប់បុគ្គលិក ព្រមទាំងការបំពាក់សម្ភារៈបរិក្ខារពេទ្យដូចជាមីក្រូទស្សន៍ និងម៉ាស៊ីនបង្វិលឈាមជាដើម។

គម្រោងនេះនឹងជួយសម្រួលដល់អ្នកជំនាញសុខាភិបាលនៅមន្ទីរពេទ្យក្នុងការផ្តល់សេវាដែលរួមទាំងសេវាសម្រាកព្យាបាល និងការធ្វើរោគវិនិច្ឆ័យទៅលើជំងឺគ្រុនចាញ់ ជំងឺថ្លើម មេរោគអេដស៍/ជំងឺអេដស៍ និង ជំងឺគ្រុនឈាមជាដើម ដែលនឹងអាចបំពេញបន្ថែមទៅលើសេវាដែលផ្តល់ដោយមន្ទីរពេទ្យខេត្ត និងមណ្ឌលសុខភាពនៅតាមស្រុកនានាក្នុងខេត្តរតនគីរី។ យើងសង្ឃឹមថាប្រជាពលរដ្ឋប្រមាណ៥០,០០០នាក់ដែលរស់នៅក្នុងស្រុកបរកែវ ស្រុកអូរយ៉ាដាវ និងស្រុកអណ្តូងមាសនឹងទទួលបានអត្ថប្រយោជន៍ពីការកែលម្អសេវាសុខាភិបាលក្នុងគម្រោងនេះ។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខាថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន ហើយអគារមន្ទីរពេទ្យព្រមទាំងបរិក្ខារពេទ្យថ្មីនឹងត្រូវបានថែទាំយ៉ាងល្អដោយមន្ទីរពេទ្យបង្អែកស្រុកបរកែវ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។ សូមអរគុណ!